**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
លេខ:០១២ /០៨ របក. អ.គ.គ

**របាយការណ៍ ស្តីពីកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងតុលាការគំរូ ដើម្បីអនុម័តលើសេចក្តីព្រាងឯកសារស្តីពីស្តង់ដារ និងលក្ខណៈវិនិច្ឆ័យសម្រាប់តុលាការគំរូកម្ពុជា នៅសណ្ឋាគារអាំងទ័រកុងទីណុងតាល់**

ឆ្នាំពីរពាន់ប្រាំបី ខែ មេសា ថ្ងៃទី ម្ភៃប្រាំបួន វេលាម៉ោងប្រាំបួន នៅសាលប្រជុំសណ្ឋាគារអាំងទ័រកុងទីណុងតាល់ រាជធានីភ្នំពេញ មានកិច្ចប្រជុំមួយនៃក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោង តុលាការគំរូកម្ពុជា ក្រោមអធិបតីភាពរបស់ ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ និងជាតំណាងឯកឧត្តមប្រធានក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងតុលាការគំរូ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាង ឯកសារស្តីពីស្តង់ដារ និងលក្ខណៈវិនិច្ឆ័យសម្រាប់តុលាការគំរូកម្ពុជា។ សមាសភាពអ្នកចូលរួមប្រជុំ មានដូចបញ្ជីជូនភ្ជាប់មកជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តមប្រធានអង្គប្រជុំបានថ្លែងមតិស្វាគមន៍ និងជម្រាបជូនអង្គប្រជុំ ពីប្រវត្តិគម្រោង តុលាការគំរូ ដែលស្ថិតនៅក្នុងទិសដៅជាយុទ្ធសាស្រ្តទី៥ កម្មវិធីសកម្មភាពលេខ ៥.៣.២ របស់កំណែទម្រង់ច្បាប់ និងតុលាការ ។ តុលាការគំរូនេះត្រូវបានផ្តួចផ្តើមនៅខេត្តកណ្តាល ដោយគម្រោង CCJAPII ។ គម្រោងតុលាការ គំរូបានពង្រីកបន្ថែមទៅដល់តុលាការក្រុងភ្នំពេញ ខេត្តកំពង់ចាម និងខេត្តបន្ទាយមានជ័យ ។ តុលាការគំរូ មិនសំដៅតែទៅលើរឿងព្រហ្មទណ្ឌតែមួយមុខប៉ុណ្ណោះទេ គឺគ្របដណ្តប់ទៅលើគ្រប់រឿង និងលើតុលាការទាំងមូល។ ឯកសារដែលយកមកដាក់ជូន ក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងតុលាការគំរូពិនិត្យ និងអនុម័ត នៅពេលនេះ គឺជាលទ្ធផលនៃការប្រជុំពិភាក្សាពិនិត្យ និងកែលំអរបស់ក្រុមការងារបច្ចេកទេសសម្រាប់ គម្រោងតុលាការគំរូ កាលពីថ្ងៃទី ០៥ ដល់ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ និង ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដោយមានការចូលរួមពីក្រុមអ្នកឯកទេសដែលមកពីប្រទេសដាណឺម៉ាក និងពីគម្រោង CCJAPIII ។ ដើម្បីជូន ក្រុមការងារជាន់ខ្ពស់ជ្រាប អំពីការវិវត្តិន៍នៃដំណើរការរៀបចំ និងខ្លឹមសារនៃឯកសារនេះ ឯកឧត្តមប្រធានអង្គប្រជុំបានអញ្ជើញវាគ្មិន បីនាក់ធ្វើបទអន្តរាគមន៍ ៖

1- បទអន្តរាគមន៍របស់ លោក Bent Vase ដែលជាទីប្រឹក្សាយុទ្ធសាស្ត្រមកពី DIHR ស្តីពីជំហាន និង ដំណាក់កាលនៃគម្រោងតុលាការគំរូ

2- លោក គង់ ផល្លៈ ដែលជាលេខាធិការគម្រោងតុលាការគំរូធ្វើរបាយការណ៍ ស្តីពីការអនុវត្តគម្រោង តុលាការគំរូ

3- បទអន្តរាគមន៍របស់ ឯកឧត្តម ហេង ជី ដែលជាទីប្រឹក្សាជាន់ខ្ពស់របស់គម្រោង ស្តីពីខ្លឹមសារសេចក្តីព្រាងលើលក្ខណៈវិនិច្ឆ័យសម្រាប់តុលាការគំរូ ។

លោក Bent Vase បានបង្ហាញជូននូវជំហាន និងដំណាក់កាលនៃគម្រោងតុលាការគំរូ ដោយជម្រាបជូន ពីរចនាសម្ព័ន្ធកម្មវិធីដំណើរការលើការវិភាគក្នុងការរៀបចំឯកសារ និងបញ្ជីសំណួរដំណើរការធ្វើផែនការ ផែនការគម្រោង និងថវិកា ប្រតិទិនគ្រប់គ្រងគម្រោង កិច្ចព្រមព្រៀងផ្តល់មូលនិធិសូចនាករបញ្ជាក់ពីការជឿនលឿន ដោយមានការតាមដាន និងការរាយការណ៍ដូចមានកំណត់នៅក្នុងគម្រោងសូចនាការនៃភាពជឿនលឿន សម្រាប់តុលាការគំរូ ។

លោក គង់ ផល្លៈ បានធ្វើរបាយការណ៍អំពីការអនុវត្តគម្រោងតុលាការគំរូ ចាប់ពីខែ ឧសភា ឆ្នាំ ២០០៧ ដល់ ខែមេសា ឆ្នាំ ២០០៨ អំពីប្រវត្តិគម្រោងតុលាការគំរូកម្ពុជា ការអនុវត្តគម្រោងតុលាការគំរូ និងទិសដៅបន្ត ។ ( សូមមើលឯកសារដាក់ជូនភ្ជាប់ជាមួយនេះ )

ឯកឧត្តម ហេង ជី បានបង្ហាញជូនខ្លឹមសារឯកសារ ស្តីពីស្តង់ដារ លក្ខណៈវិនិច្ឆ័យ និងបញ្ជីសំណួរ ។ លើសពីនេះ ឯកឧត្តមបានបង្ហាញពីរចនាសម្ព័ន្ធតុលាការកម្ពុជានៅជាន់ដំបូង ដោយមានគូសសេមាបង្ហាញ ពីការបែងចែកជាសភាតាម ផ្នែកនីមួយៗ ទៅតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី ដែលទើបនឹងចូលជាធរមានក្នុងពេលថ្មីៗនេះ ។ ឯកឧត្តមបានជម្រាបជូននូវកាតព្វកិច្ចរបស់មន្ត្រីតុលាការ រួមមាន ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ដើម្បីឆ្លើយតបទៅនឹងស្តង់ដារ និងលក្ខណៈវិនិច្ឆ័យសម្រាប់តុលាការគំរូកម្ពុជា នៅក្នុងដំណាក់កាលនីមួយៗ ចាប់ពីដំណាក់កាលទទួលពាក្យបណ្តឹងរហូតដល់ដំណាក់កាលបិទ បញ្ជីរឿងក្តី ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានសង្ខេបជូនក្រុមការងារជាន់ខ្ពស់ពីការកំណត់យកស្តង់ដារទាំង១១ ដែលបានដកស្រង់ពីបទដ្ឋានអន្តរជាតិ ហើយនឹងការសិក្សាពិចារណារកលក្ខណៈ វិនិច្ឆ័យជាតិ និងអន្តរជាតិ សម្រាប់តុលាការគំរូនេះ ចាប់តាំងពីដំណាក់កាលទទួលពាក្យបណ្តឹងរហូតដល់ដំណាក់កាលទី១០ គឺការជូន ដំណឹងជាទូទៅអំពីតុលាការ និងការសហការ ។ ឯកឧត្តមបានបញ្ជាក់ថា បន្ទាប់ពីបានការអនុម័តពីក្រុមការងារ ជាន់ខ្ពស់ទៅអ្នកឯកទេសមួយក្រុម និងចុះទៅជួបថ្នាក់គ្រប់គ្រងរបស់តុលាការគំរូនីមួយៗដើម្បីរៀបចំធ្វើផែនការ ការងារសម្រាប់តុលាការផ្ទាល់មួយៗ និងផែនការសកម្មភាព ដើម្បីធ្វើយ៉ាងណាអោយតុលាការនោះ ត្រូវបាន លើកកំពស់ទៅដល់ស្តង់ដារដែលបានកំណត់ ។

ឯកឧត្តម ហាង់រ៉ូ វ៉ាកេន អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ បានកត់សំគាល់លើសេមារបស់ របនាសម្ព័ន្ធតុលាការគំរូ នៅតុលាការជាន់ដំបូងថា អាចធ្វើអោយអ្នកមើលយល់ច្រឡំថា ចៅក្រមស៊ើបសួរ នៅក្រោមព្រះរាជអាជ្ញា ។ ដូច្នេះ ឯកឧត្តមសូមអោយកែសម្រួលសេមាឡើងវិញ ។ ឯកឧត្តមបានចាប់ អារម្មណ៍ថា ការរៀបចំតុលាការគំរូ ផ្តោតធ្ងន់តែទៅលើចៅក្រមអសនៈ ដោយមិនសូវផ្តោតលើស្ថាប័ន អយ្យការ ដូចនេះមិនអាចអនុវត្តបានទេ ព្រោះអយ្យការក៏ជាផ្នែកមួយ របស់តុលាការដែរ ។

ឯកឧត្តម ហេង ជី បានបញ្ជាក់បន្ថែមជូនអង្គប្រជុំថា ចៅក្រមស៊ើបសួរត្រូវនៅជាមួយចៅក្រម អសនៈមិនមែន នៅក្រោមព្រះរាជអាជ្ញាទេ ។ ចំណែកឯព្រួញចុះឡើងគ្រាន់តែជាសហប្រតិបត្តិការការងារ ប៉ុណ្ណោះ យើងអាចធ្វើការកែសម្រួលឡើងវិញបាន ។ គម្រោងតុលាការគំរូចំពោះចៅក្រមអសនៈ និងអយ្យការ ត្រូវអនុវត្តរួមជាមួយគ្នាដើម្បីរៀបចំតុលាការគំរូនេះ មិនមែនផ្តោតតែទៅលើចៅក្រមអសនៈ មិនគិតគូរដល់ អយ្យការនោះទេ ។

សរុបមក ក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងតុលាការគំរូបានទទួលយកឯកសារ ដោយ ពុំមានការជំទាស់អ្វីទេ គ្រាន់តែដោយសារឯកឧត្តម ហាង់រ៉ូ វ៉ាកេន មានប្រសាសន៍ថា មិនមានពេល គ្រប់គ្រាន់ សម្រាប់មើលឯកសារឯកឧត្តម ស៊ុយ ម៉ុងលាង ប្រធានអង្គប្រជុំបាន ទុកពេលពីរ សប្តាហ៍ដើម្បីជូនឯកឧត្តម ហាង់រ៉ូ វ៉ាកេន និងសមាជិកផ្តល់យោបល់បន្ថែម ។ បើសិនក្នុងរយៈពេលពីរ សប្តាហ៍គ្មានមតិយោបល់ទេ នោះសេចក្តីព្រាងលើស្តង់ដារ និងលក្ខណៈវិនិច្ឆ័យ សម្រាប់តុលាការគំរូ នឹងត្រូវសម្រេចថា បានទទួលការឯកភាព អនុម័តពីក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងតុលាការគំរូ ជាផ្លូវការ ។

ក្រុមការងារអ្នកឯកទ្ទេសដែលនឹងចុះទៅជួបតុលាការគំរូមានសមាសភាពដូចខាងក្រោម ៖

១- ឯកឧត្តម ហេង ជី
២- លោក Ben Schultz
៣- លោក គង់ ផល្លៈ
៤- លោក Max Howlett

ក្រុមការងារនេះមានភារៈកិច្ចចុះទៅតុលាការគំរូនីមួយៗ ដើម្បីជួយរៀបចំផែនការការងារ និង ផែនការសកម្មភាពដែលបញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ននៃតុលាការនីមួយៗជួបការខ្វះខាត និងតម្រូវការ ដើម្បីឆ្លើយតបទៅនឹង ស្តង់ដារដែលបានកំណត់ ។

អង្គប្រជុំបានប្រព្រឹត្តទៅដោយរលូន ហើយបានបញ្ចប់នៅម៉ោងដប់ពីរគត់ នាថ្ងៃខែឆ្នាំដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៨*

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ　　　　　　　　　　　　　　　　　　អ្នកធ្វើរបាយការណ៍

ស៊ុយ ម៉ុងលាង　　　　　　　　　　　　　　　　　　សេង វ៉ាន់ដា

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
នាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨

១- ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង
២- ឯកឧត្តម ហេង ជី ក្រុមប្រឹក្សាអ្នកច្បាប់
៣- ឯកឧត្តម ហង់រ៉ូ វ៉ាកេន អគ្គព្រះរាជអាជ្ញា
៤-ឯកឧត្តម ខៀវ សាម៉េត ប្រធានតុលាការខេត្តកណ្តាល
៥-ឯកឧត្តម ទី ណោង អនុប្រធានសាលាឧទ្ធរណ៍
៦- ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង
៧- ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង
៨- ឯកឧត្តម ចន្ទ័ មនោ នាយកខុទ្ទកាល័យ និងជាទីប្រឹក្សាអមក្រសួងយុត្តិធម៌
៩- លោក ឈឹម ស៊ីផល ចៅក្រមតុលាការកំពូល
១០- លោក អ៊ីវ គឹមស្រ៊ី ចៅក្រមតុលាការក្រុងភ្នំពេញ
១១- Mr. Ben Schultz, Adviser (CCJAP III)
១២- លោក ជ សៀកវេង CCJAP
១៣- លោក បូន សុមុនី ប្រធានគម្រោងរដ្ឋបាល និងហិរញ្ញវត្ថុ
១៤- លោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល
១៥- លោក ប្លង់ ឆ្លាម ប្រធានតុលាការខេត្តកំពង់ចាម
១៦- លោក អាំង មាលតី ប្រធានតុលាការខេត្តបន្ទាយមានជ័យ
១៧- លោក សន កែវ តំណាងអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ
១៨- លោក យឹម ចំណាប់ភក្តី ប្រធានការិយាល័យពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
១៩- លោកស្រី Katherine Mitchell លេខាធិការទី២ សហប្រតិបត្តិការអភិវឌ្ឍន៍ AusAid
២០- លោក Reed Aeschliman នាយកការិយាល័យអភិវឌ្ឍន៍ទូទៅ AusAid
២១- លោកស្រី Momoko Hotta ជមន្ទួយការប្រធានសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA

២២- លោក គង់ ផល្ល: អនុប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់
២៣- កញ្ញា ផាន ពិសីនលក្ខណ៍ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ
២៤- លោកស្រី យិន កក្កដា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ
២៥- លោក សួន វីរ: មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ
២៧- លោក ហួរ ភ័ត្រា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ
២៨- លោក កួយ សៅ អនុប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
២៩- លោក ឃ្លោក ដារ៉ា ប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
៣០-លោក ជឹង ផេងស្រ៊ួយ ប្រធានក្រុមគម្រោងបណ្ណសារ និងកំព្យូទ័រ
៣១-លោកស្រី ស្រី ប៊ុណ្ណារ័ត្ន អនុប្រធានក្រុមគម្រោងបណ្ណសារ និងកំព្យូទ័រ
៣២-លោកស្រី Kana Manabe (Legal Advisor) MOJ/JICA
៣៣- Rajan Shah (Access to Justice Advisor) EWMI
៣៤- Sar senera
៣៥- Clint Hanna, USDOD
៣៦-លោក សេង រិទ្ធិ ី USAID
៣៧- Arthi Patel AUSAID
៣៨-លោក ឆៃ លីអនុប្រធានគម្រោងកំណែទម្រង់យុត្តិធម៌